# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ: ៦៧១ (ឥ)ក្រ៩
ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ: ១៣០៣
ចុះថ្ងៃទី២២.០២.២០២០
សំណុំរឿងស៊ើបសួរលេខ: ៩៥៧
ចុះថ្ងៃទី ២៤.០២.២០២០
សំណុំរឿងជំនុំជម្រះលេខ: ៤៨៦២
ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩

បានបើកសវនាការជាអសាធារណៈនៅសាលជំនុំជម្រះទី៣ នៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០នាទីព្រឹក ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកអនុប្រធាន [redacted] ជាប្រធានក្រុមប្រឹក្សា

លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣០៣ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានកំរិតវប្បធម៌ថ្នាក់ទី៨ មានទីកន្លែងកំណើត ភូមិទួលស[redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួន ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រ៉ា(រស់) ម្ដាយឈ្មោះ [redacted] សុភ័ក្រ(រស់) នៅលីវ ជាអនីតិជន (ក្នុងឃុំ)។

-ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣៣១(រ)ដ.ឃ.ដ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

២-ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានកំរិតវប្បធម៌ថ្នាក់ទី៦ មានទីកន្លែងកំណើត ភូមិទួ[redacted]រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួន ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សឿន(រស់) ម្ដាយឈ្មោះ [redacted] ចាន់ធី(រស់) នៅលីវ ជាអនីតិជន (ក្នុងឃុំ)។

-ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣២៨(រ)ដ.ឃ.ដ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

៣-ឈ្មោះ [redacted] សុខឿន ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានកំរិត



Scanned with CamScanner

វប្បធម៌ថ្នាក់ទី៨ មានទីកន្លែងកំណើត ភូមិផ្[redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួន ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សឿន(រស់) ម្តាយឈ្មោះ [redacted] ចាន់នី (រស់) នៅលីវ ជានីតិជន (ក្នុងឃុំ)។

-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣២៩(វ)ដ.ឃ.ដ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

៤-ឈ្មោះ [redacted] ពិទូ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ មានកំរិតវប្បធម៌ថ្នាក់ទី១២ មានទីកន្លែងកំណើត ភូមិទួល[redacted] រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួន ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុខា(ស្លាប់) ម្តាយឈ្មោះ [redacted] ស៊ីនតូ (ស្លាប់) នៅលីវ ជាអនីតិជន (ក្នុងឃុំ)។

-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៣៣០(វ)ដ.ឃ.ដ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

ជាប់ចោទពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០នាទី កម្លាំងសមត្ថកិច្ចនគរបាលរដ្ឋបាលប៉ុស្តិ៍ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានចុះល្បាតក្នុងមូលដ្ឋានដល់ចំណុច ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានប្រទះឃើញជនជាប់ចោទឈ្មោះ [redacted] សុខឿន, ឈ្មោះ [redacted] ពិសិដ្ឋ, ឈ្មោះ [redacted] ពិទូ និងឈ្មោះ [redacted] សុខហេង កំពុងប្រើប្រាស់គ្រឿងញៀនក្នុងផ្ទះខុកចោល ដោយសមត្ថកិច្ចរកឃើញ ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន។ បន្ទាប់មកសមត្ថកិច្ចក៏នាំខ្លួនជនជាប់ចោទខាងលើមកសាកសួរ និងធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន ជាលទ្ធផល វិជ្ជមាន(មានសារធាតុញៀនក្នុងទឹកនោម)ហើយក៏ឃាត់ខ្លួន រួមនឹងវត្ថុតាង រួចហើយកសាងសំណុំរឿងបញ្ជូនមកយព្រះរាជអាជ្ញា អមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍លេខ ០៤៣/២០ ដ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០ របស់អធិការនគរបាលខណ្ឌឫស្សីកែវ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១០៦១ អ.យ.ង ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៧៦៣ អ.យ.គ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ របស់តំណាងអយ្យការអម



Scanned with CamScanner

សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបង្គាប់រក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ ៤៥៦៦(វ)ដ.ឃ.ង, ៤៥៦៧(វ)ដ.ឃ.ង ៤៥៦៨(វ)ដ.ឃ.ង និងលេខ ៤៥៦៨(វ)ដ.ឃ.ង ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២២៧០(វ) ដ.ង ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នារពលសមនាភារ

-ជនជាប់ចោទឈ្មោះ [redacted] សុខឿន ឆ្លើយថា នៅថ្ងៃមិនចាំ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោងប្រហែល ០៩យប់ ខ្លួនកំពុងអង្គុយលេងហ្គេមនៅក្នុងទូរស័ព្ទដៃនៅក្នុងផ្ទះរបស់ប្អូនឈ្មោះ [redacted] ពិសិដ្ឋ និងមានឈ្មោះ [redacted] សុខហេង និងឈ្មោះ [redacted] ពិទូ ក៏បានអង្គុយលេងនៅក្នុងផ្ទះនោះដែរ ស្រាប់តែមានប្រជាការពារភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ មានគ្នាប្រហែល ១៥នាក់ បានចុះមកដល់ផ្ទះឈ្មោះ [redacted] ពិសិដ្ឋ ហើយឃាត់ខ្លួនពួកខ្លួនទាំងអស់ និងធ្វើការឆែកឆេររកមិនឃើញថ្នាំញៀនទេ ហើយក៏បាននាំពួកខ្លួនទៅប៉ុស្តិ៍ធ្វើការសាកសួរ និងធ្វើតេស្តទឹកនោម ឃើញមានសារធាតុញៀន។ ខ្លួនប្រើប្រាស់ថ្នាំញៀនរយៈពេលបួនខែហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ពិទូ ឆ្លើយថា កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោងប្រហែល ០៩យប់ ខ្លួនកំពុងអង្គុយលេងនៅមុខផ្ទះឈ្មោះ [redacted] សុខឿន និងមានឈ្មោះ [redacted] សុខហេង និងឈ្មោះ [redacted] ពិសិដ្ឋ ស្រាប់តែមានប្រជាការពារភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ មានគ្នាប្រហែល ១៥នាក់ បានចុះមកដល់ផ្ទះឈ្មោះ [redacted] ពិសិដ្ឋ ហើយឃាត់ខ្លួនពួកខ្លួនទាំងអស់ និងធ្វើការឆែកឆេររកមិនឃើញថ្នាំញៀនទេ ហើយក៏បាននាំពួកខ្លួនទៅប៉ុស្តិ៍ធ្វើការសាកសួរ និងធ្វើតេស្តទឹកនោម ឃើញមានសារធាតុញៀន។ ខ្លួនប្រើប្រាស់ថ្នាំញៀនរយៈពេលប្រហែលបីខែហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ឆ្លើយថា នៅថ្ងៃមិនចាំ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោងប្រហែល ០៩យប់ ខ្លួនកំពុងអង្គុយលេងហ្គេមនៅក្នុងទូរស័ព្ទដៃនៅក្នុងផ្ទះ ដែលក្នុងនោះមានគ្នា ០៤នាក់ មានឈ្មោះ ជៀប សុខឿន និងមានឈ្មោះ [redacted] សុខហេង និងឈ្មោះ [redacted] ពិទូ ក៏បានអង្គុយលេងនៅក្នុងផ្ទះនោះដែរ ស្រាប់តែមានប្រជាការពារភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ មានគ្នាប្រហែល ១៥នាក់ បានចុះមកដល់ផ្ទះឈ្មោះ [redacted] ពិសិដ្ឋ ហើយឃាត់ខ្លួនពួកខ្លួនទាំងអស់ និងធ្វើការឆែកឆេររកមិនឃើញថ្នាំញៀនទេ ហើយក៏បាននាំពួកខ្លួនទៅប៉ុស្តិ៍ធ្វើការសាកសួរ និងធ្វើតេស្តទឹកនោម ឃើញមានសារធាតុញៀន។ ខ្លួនប្រើប្រាស់ថ្នាំញៀនរយៈពេលបួនខែហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុខហេង ឆ្លើយថា កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោងប្រហែល ០៩យប់ ខ្លួនបានអង្គុយលេងហ្គេមនៅមុខផ្ទះរបស់ប្អូនឈ្មោះ [redacted] ពិសិដ្ឋ មានឈ្មោះ [redacted] សុខឿន និងឈ្មោះ [redacted] ពិទូ ស្រាប់តែមានប្រជាការពារភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ បានចុះមកដល់ផ្ទះឈ្មោះ [redacted] ពិសិដ្ឋ ហើយឃាត់ខ្លួនពួកខ្លួនទាំងអស់ និងធ្វើការ



Scanned with CamScanner

ផែកនេះរកមិនឃើញថ្នាំញៀនទេ ដោយឃើញមានប្រដាប់ប្រើប្រាស់ថ្នាំញៀននៅក្នុងផ្ទះ ហើយក៏បាននាំពួកខ្លួនទៅប៉ុស្តិ៍ធ្វើការសាកសួរ និងធ្វើតេស្តទឹកនោម ឃើញមានសារធាតុញៀន។ ខ្លួនពិតជាបានប្រើប្រាស់ថ្នាំញៀនមែន។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា៖ ពិតជាមានអង្គហេតុចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ហើយចម្លើយសារភាពរបស់ជនជាប់ចោទស៊ីសង្វាក់ទៅនឹងភស្តុតាងមានក្នុងសំណុំរឿង ដូចនេះ តំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១៧៦៣ អ.យ.ក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសុំឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា

ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ឃើញថា កូនក្តីខ្លួនពុំមានធាតុផ្សំពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនឡើយ សមត្ថកិច្ចបានរកឃើញឧបករណ៍ប្រើប្រាស់គ្រឿងញៀនក៏ដោយ នៅពេលឃាត់ខ្លួនពុំបានដកហូតគ្រឿងញៀនឡើយ ដូចនេះកូនក្តីខ្លួនពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមការអូសទាញរបស់មិត្តភក្តិ និងសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ រើត ពិសិដ្ឋ និងឈ្មោះ ជា សុខហេង រួចខ្លួនពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងផ្តល់ស្ថានសម្រាលទោសពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

-ជនជាប់ចោទឈ្មោះ [redacted] សុខធឿន បាននិយាយជាសម្តីចុងក្រោយថា សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បាននិយាយជាសម្តីចុងក្រោយថា សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ពិទូ បាននិយាយជាសម្តីចុងក្រោយថា សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] សុខហេង បាននិយាយជាសម្តីចុងក្រោយថា សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-ពិតជាមានអង្គហេតុ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ប្រាកដមែន ។

២-អង្គហេតុ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលកើតឡើងនៅកន្លែងដូចបានបញ្ជាក់ខាងលើ ពិតជាប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុខធឿន ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] ពិសិដ្ឋ

ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] ពិទូ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ប្រាកដមែន។

៣-អង្គហេតុ ប្រព្រឹត្តឡើងដោយជនជាប់ចោទ និងទីកន្លែងដូចខាងលើ មានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្មទណ្ឌ ដូចជាការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមដីកាសន្និដ្ឋានស្ថាពរលេខ ១៧៦៣ អ.យ.ភ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ (ឡ) ៨.៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ប្រាកដមែន ។

៤-ជនជាប់ចោទឈ្មោះ [redacted] សុខធឿន, ឈ្មោះ [redacted] ពិសិដ្ឋ, ឈ្មោះ [redacted] ពិទូ និងឈ្មោះ [redacted] សុខហេង បានឆ្លើយប្រហាក់ប្រហែលគ្នាថា នៅពេលពួកខ្លួនកំពុងអង្គុយលេងនៅក្នុងផ្ទះភូមិចុងខ្សាច់ ស្រាប់តែមានប្រជាការពារភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ មានគ្នាប្រហែល ១៥នាក់ បានចុះមកដល់ផ្ទះឈ្មោះ [redacted] ពិសិដ្ឋ ហើយឃាត់ខ្លួនពួកខ្លួនទាំងអស់ និងធ្វើការឆែកឆេររក មិនឃើញថ្នាំញៀនទេ ហើយក៏បាននាំពួកខ្លួនទៅប៉ុស្តិ៍ធ្វើការសាកសួរ និងធ្វើតេស្តទឹកនោម ឃើញមានសារធាតុញៀន។

៥-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានទោសលើជនជាប់ចោទឈ្មោះ [redacted] សុខធឿន, ឈ្មោះ [redacted] ពិសិដ្ឋ, ឈ្មោះ [redacted] ពិទូ និងឈ្មោះ [redacted] សុខហេង ថា ពិតជាបានប្រព្រឹត្តបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ និងសុំឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៦-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា សុំឱ្យតុលាការសម្រេច ឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] សុខហេង រួចខ្លួនពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងផ្តល់ស្ថានសម្រាលទោសពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តុលាការគប្បីពិចារណា។

៧-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] សុខធឿន ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ពិទូ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ជា អនីតិជន មិនទាន់ចេះពិចារណានូវអំពើរបស់ខ្លួនដែលប្រព្រឹត្តនៅឡើយទេ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] សុខធឿន និងឈ្មោះ [redacted] ពិទូ ក៏បានសំណូមតុលាការពីស្ថានសម្រាលទោស។

តាមការពិនិត្យអំពើរបស់ជនជាប់ចោទ ឃើញថា ពុំបានបង្កព្យសនកម្មធ្ងន់ធ្ងរ ម្យ៉ាងទៀតដើម្បីអាចឱ្យជាប់ចោទកែប្រែខ្លួនចូលក្នុងសង្គមឱ្យបានល្អ និងជៀសវាងការប្រព្រឹត្តបទល្មើសជាថ្មី តុលាការគប្បីសម្រេចអំពីការព្យួរទោសសាកល្បងសម្រាប់ជនជាប់ចោទយោងតាមមាត្រ ១១៧, ១១៨ នៃក្រមព្រហ្មទណ្ឌ និងតម្រូវឱ្យទណ្ឌិតគោរពវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកមួយចំនួនយោងតាមមាត្រា ១១៩,១២០ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] សុខឿន ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] ពិទូ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ២(ពីរ)ឆ្នាំ តែទោសត្រូវអនុវត្តទោសក្នុងពន្ធនាគារ ១០(ដប់)ខែ ទោសសល់ពីនេះត្រូវព្យួរដោយកំណត់រយៈពេលសាកល្បង ១៨(ដប់ប្រាំបី)ខែ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០(ពីរលាន)រៀល ដើម្បីជាប្រយោជន៍ថវិការដ្ឋ ពីបទ: ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] សុខហេង ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១(មួយ)ឆ្នាំ តែទោសត្រូវអនុវត្តទោសក្នុងពន្ធនាគារ ៦(ប្រាំមួយ)ខែ ទោសសល់ពីនេះត្រូវព្យួរដោយកំណត់រយៈពេលសាកល្បង ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១.០០០.០០០(មួយលាន)រៀល ដើម្បីជាប្រយោជន៍ថវិការដ្ឋ ពីបទ: ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ផ្លូវរថភ្លើង ភូមិចុងខ្សាច់ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ទណ្ឌិតត្រូវអនុវត្តវិធានការត្រួតពិនិត្យដូចតទៅ៖

ក-ទណ្ឌិតត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬ បុគ្គលដែលព្រះរាជអាជ្ញាប្រគល់អំណាចឱ្យ។

ខ-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាប្រគល់អំណាចឱ្យ។

គ-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់អាសយដ្ឋាន និងមុខរបររបស់ខ្លួន។

៤-ទណ្ឌិតត្រូវអនុវត្តកាតព្វកិច្ចដោយឡែកដូចខាងក្រោម៖

ក-ទណ្ឌិតមិនត្រូវប្រើប្រាស់ ជួញដូរ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនដោយខុសច្បាប់។

ខ-ទណ្ឌិតមិនត្រូវសេពគប់ជនដែលពាក់ព័ន្ធនឹងគ្រឿងញៀនឡើយ។

៥-សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃអង្គារ ៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

អនុប្រធានសាលាដំបូង

[redacted]